អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
## សហភាពអឺរ៉ុបសម្រេចផ្តល់ជំនួយថវិកាចំនួន ៨,៩ លានអឺរ៉ូដល់ អ.វ.ត.ក

សហភាពអឺរ៉ុបបានសម្រេចផ្តល់ជំនួយថវិកាថ្មីចំនួន ៨,៩ លានអឺរ៉ូ ជូនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់គម្រោងថវិកាឆ្នាំ ២០១៥ និង ២០១៦។ សម្រាប់ឆ្នាំ ២០១៥នេះ សហភាពអឺរ៉ុប ផ្តល់វិភាគទានចំនួន ២ លានអឺរ៉ូ ដល់ភាគីជាតិ និងចំនួន ៣,៥ លានអឺរ៉ូដល់ភាគីអន្តរជាតិនៃ អ.វ.ត.ក។

ការបែងចែកថវិកានៅសល់ចំនួន ៣,៤ លានអឺរ៉ូ នឹងត្រូវសម្រេច នៅឆ្នាំ ២០១៦។ សហភាពអឺរ៉ុបជាម្ចាស់ជំនួយធំមួយក្នុងចំណោមម្ចាស់ជំនួយធំៗរបស់ អ.វ.ត.ក ហើយជាមួយនឹងវិភាគទានថ្មីនេះ សហភាពអឺរ៉ុបបានផ្តល់ជំនួយថវិកាសរុបចំនួន ១៦,២ លានអឺរ៉ូ ចាប់តាំងពី អ.វ.ត.ក ដំណើរការនៅឆ្នាំ ២០០៦ រហូតមកដល់ពេលនេះ។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានមានប្រសាសន៍ថា៖ «ក្នុងនាម អ.វ.ត.ក យើងខ្ញុំសូមបង្ហាញការវាយតម្លៃខ្ពស់ចំពោះការគាំទ្រថវិការបស់សហភាពអឺរ៉ុប។ ជំនួយហិរញ្ញវត្ថុថ្មីនឹងជួយដល់ការងារយុត្តិធម៌ក្នុងការនាំយកមកជំនុំជម្រះក្តី មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងរបបខ្មែរក្រហម »។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ
neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org